ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញ៖ ថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០១៥ ដោយ អគ្គនាយកដ្ឋានពន្ធដារ

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពីកិច្ចប្រជុំពិភាក្សាការងារ រវាងអគ្គនាយកដ្ឋានពន្ធដារ
## និងតំណាងធុរជនដែលប្រកបធុរកិច្ចក្នុងវិស័យសាងសង់បុរី និងសំណង់ផ្ទះល្វែង

នាវេលាម៉ោង ០៩:០០ នាទីព្រឹក ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៥ នៅអគ្គនាយកដ្ឋានពន្ធដារ បានបើកកិច្ចប្រជុំពិភាក្សាការងារជាមួយតំណាងធុរជនដែលប្រកបអាជីវកម្មលើវិស័យសាងសង់សំណង់ផ្ទះល្វែងមកពីសំណង់បុរីផ្ទះល្វែងផ្សេងៗ នៅក្នុងរាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងថ្នាក់ដឹកនាំរបស់អគ្គនាយកដ្ឋានពន្ធដារជាច្រើនរូប។



ជាកិច្ចចាប់ផ្តើម ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលបានសម្តែងកិច្ចស្វាគមន៍យ៉ាងកក់ក្តៅចំពោះលោកឧកញ៉ា លោក-លោកស្រីជាតំណាងម្ចាស់បុរី សំណង់ផ្ទះល្វែងដែលមានវត្តមានក្នុងកិច្ចប្រជុំនាព្រឹកនេះ។ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលបានសម្តែងការកោតសរសើរចំពោះការសហការចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិរបស់លោកឧកញ៉ា លោក-លោកស្រី តាមរយៈការវិនិយោគសំណង់បុរីផ្ទះល្វែង ដែលធ្វើឲ្យមុខមាត់ទីក្រុងកាន់តែល្អប្រសើរឡើង និងជាការរួមចំណែកក្នុងការបង់ពន្ធជូនរដ្ឋ ព្រោះថា វិស័យសំណង់គឺជាសសរស្តម្ភមួយក្នុងចំណោមចតុស្តម្ភសំខាន់ៗដែលទ្រទ្រង់សេដ្ឋកិច្ចជាតិ។

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលបានជម្រាបជូនធុរជនដែលមានវត្តមានក្នុងកិច្ចប្រជុំព្រឹកនេះផងដែរថា កន្លងមករាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី** តែងតែមានការជំរុញលើកទឹកចិត្តចំពោះវិនិយោគិនដែលបណ្តាក់ទុនលើវិស័យសាងសង់សំណង់បុរី និងផ្ទះល្វែង។ តាមការវិភាគសេដ្ឋកិច្ច វិស័យសំណង់មានការរីក

ដុះដាលយ៉ាងគគ្រឹកគគ្រេង ក៏ប៉ុន្តែការបង់ពន្ធដារវិញ ហាក់នៅមិនទាន់ឆ្លើយតបទៅនឹងសកម្មភាពសេដ្ឋកិច្ចនោះទេ។ ហេតុនេះហើយ ទើបធ្វើឲ្យមានការជួបប្រជុំគ្នានាពេលនេះ ដើម្បីអគ្គនាយកដ្ឋានពន្ធដារផ្សព្វផ្សាយ ពន្យល់ពីកាតព្វកិច្ចសារពើពន្ធ និងសិទ្ធិរបស់អ្នកជាប់ពន្ធដែលប្រកបអាជីវកម្មលើវិស័យអភិវឌ្ឍលំនៅដ្ឋាន ឬសាងសង់ផ្ទះល្វែងសម្រាប់លក់។ ព្រមជាមួយនេះ អគ្គនាយកដ្ឋានពន្ធដារនឹងស្តាប់នូវបញ្ហាប្រឈមនានាដែលធុរជនក្នុងវិស័យនេះបាននិងកំពុងជួបប្រទះ ដើម្បីស្វែងរកដំណោះស្រាយមួយសមស្រប និងអាចទទួលយកបានទាំងផ្នែកឯកជន និងទាំងផ្នែករដ្ឋបាលសារពើពន្ធ ក្នុងគោលដៅធ្វើឲ្យមានតម្លាភាពក្នុងការអនុវត្តច្បាប់ស្តីពីសារពើពន្ធ។

តាងនាមឲ្យម្ចាស់ការដ្ឋាន បុរី និងសំណង់ផ្ទះល្វែងដែលចូលរួមក្នុងកិច្ចប្រជុំថ្ងៃនេះ **លោកឧកញ៉ា លី ហួរ** បានលើកឡើងនូវផលវិបាកនានាក្នុងការអនុវត្តកាតព្វកិច្ចសារពើពន្ធ ជាពិសេស ការយល់ដឹងពាក់ព័ន្ធនឹងច្បាប់ស្តីពីសារពើពន្ធរបស់ម្ចាស់បុរី និងសំណង់ផ្ទះល្វែង នៅមានកម្រិតនៅឡើយ។ ក្នុងន័យនេះ តំណាងសំណង់បុរី ផ្ទះល្វែងស្នើសុំអគ្គនាយកដ្ឋានពន្ធដារ នូវសំណូមពរមួយចំនួន ក្នុងនោះក៏បានស្នើសុំអគ្គនាយកដ្ឋានពន្ធដារចេញលិខិតបទដ្ឋានគតិយុត្ត ឬសេចក្តីណែនាំលម្អិតដល់វិស័យសំណង់បុរី ផ្ទះល្វែង ដើម្បីបានយល់ច្បាស់ពីវិធីគណនាប្រាក់ពន្ធតាមប្រភេទពន្ធនីមួយៗដែលពាក់ព័ន្ធនឹងវិស័យនេះ។

ឆ្លើយតបទៅនឹងសំណូមពរដែលបានលើកឡើងខាងលើ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល នឹងជួយសម្រួលដល់ការបណ្តុះបណ្តាលច្បាប់ស្តីពីសារពើពន្ធដោយឥតគិតថ្លៃ ជូនគណនេយ្យកររបស់បុរី និងសំណង់ផ្ទះល្វែងទាំងនោះ។ ចំពោះសំណូមពរផ្សេងៗទៀត ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលយកទៅពិភាក្សា និងដាក់ជូនថ្នាក់ដឹកនាំក្រសួងដើម្បីពិនិត្យ និងសម្រេច ព្រោះអគ្គនាយកដ្ឋានពន្ធដារគឺជាស្ថាប័នក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធ្វើការតាមឋានានុក្រមប្រកបដោយវិជ្ជាជីវៈខ្ពស់។



ជាទីបញ្ចប់ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលបានសម្តែងការកោតសរសើរ និងអរគុណចំពោះការចូលរួមអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងទទូចស្នើឲ្យម្ចាស់អាជីវកម្មទាំងនោះអនុវត្តកាតព្វកិច្ចសារពើពន្ធ ស្របតាមច្បាប់កំណត់។

ជំនួបពិភាក្សាការងារនេះ បានបញ្ចប់នៅវេលាម៉ោង ១២ : ០០ នាទីព្រឹក នាថ្ងៃខែឆ្នាំដដែល ក្នុងបរិយាកាសស្និទ្ធស្នាល និងសហប្រតិបត្តិការខ្ពស់៕